# ចំនួនស្ត្រីដែលស្លាប់ដោយសារជម្ងឺបេះដូងមានចុះកំរិត

**Fewer U.S. Women Dying of Heart Disease**
**WUML**
**2/4/07**

យោលទៅតាមវិទ្យាស្ថានជាតិនៃសហរដ្ឋផ្នែកខាងបេះដូង, សួត, និងឈាម ហៅថា U.S. National Heart, Lung, and Blood Institute កាលពីថ្ងៃ ព្រហស្បត្តិទី 1 ខែកុម្ភៈ ឆ្នាំ 2007 កន្លងទៅនេះបានឲ្យដឹងថា ចំនួនស្ត្រីនៅក្នុងសហរដ្ឋ ដែលស្លាប់ដោយសារជម្ងឺបេះដូង មានចុះចំនួនពី មួយនាក់ក្នុងចំណោមបីនាក់ នៅ 2003 មក ពី មួយនាក់ក្នុងចំណោម 4 នាក់ក្នុងឆ្នាំ 2004។ គឺបានន័យថា ចំនួនស្ត្រីដែលស្លាប់បាត់បង់ជីវិត ដោយសារជម្ងឺបេះដូង បានចុះចំនួនជិតដល់ទៅ 17,000 នាក់ នៅចន្លោះពីឆ្នាំ 2003 ទៅឆ្នាំ 2004។

ជាមួយគ្នានេះ វិទ្យាស្ថានក៏បានចាប់អារម្មណ៍ដែរថា ចំនួនស្ត្រីដែលស្លាប់ដោយសារជម្ងឺបេះដូង មានកំរិតចុះស្មើជាលំដាប ចាប់ពីឆ្នាំ 2000 រហូតដល់ឆ្នាំ 2004។ នេះ គឺជាការចុះចំនួន ដែលគេពុំដែលបានឃើញ មកពីមុន។ លទ្ធផលនេះ បានត្រូវចុះផ្សាយកាលពីថ្ងៃព្រហស្បត្តិ ដែលជាថ្ងៃសំរាប់ស្លៀកសម្លៀកបំពាក់ពណ៌ក្រហម ដើម្បីបញ្ជាក់អំពីថ្ងៃ National Wear Red Day។ National Wear Red Day ឬថ្ងៃស្លៀកសម្លៀកបំពាក់ពណ៌ក្រហម ជាកម្មវិធីមួយ ដើម្បីជំរាបស្ត្រីៗ ឲ្យជ្រាបអំពីវិបត្តិនៃជម្ងឺបេះដូង និងដើម្បីឲ្យស្ត្រីយើងអាចរកវិធី ឬមធ្យោបាយការពារទប់ទល់នឹងជម្ងឺនេះបាន។

វេជ្ជបណ្ឌិត Elizabeth Nabel ដែលជានាយកនៃ វិទ្យាស្ថានជាតិនៃសហរដ្ឋផ្នែកខាងបេះដូង, សួត, និងឈាម មានប្រសាសន៍ថា ការចុះចំនួននៃស្ត្រីដែលស្លាប់ដោយសារជម្ងឺបេះដូងនេះ ជាសញ្ញាមួយបញ្ជាក់ឲ្យដឹង អំពីការិតខឹប្រឹងប្រែងនៃកម្មវិធីនិងអង្គការណ៍នានា ដែលបានខំជួយជ្រោមជ្រែងស្ត្រីៗ ឲ្យចាត់វិធានការណ៍ ដើម្បីការពារជីវិតរបស់ខ្លួន។ នៅឆ្នាំ 2005, ស្ត្រីចំនួន 55% បានយល់ច្បាស់អំពីជម្ងឺបេះដូង បើប្រៀបធៀបទៅនឹងឆ្នាំ 2000 ដែលមានស្ត្រី តែចំនួន 34% ប៉ុណ្ណោះ ដែលជ្រាបអំពីជម្ងឺនេះ។

អ្នកស្រីវេជ្ជបណ្ឌិតមានប្រសាសន៍បន្ថែមទៀតថា កត្តាម្យ៉ាងទៀតដែលស្ត្រីយើង យល់ច្បាស់គឺថា ជម្ងឺបេះដូងជាជម្ងឺ ចម្បងបង្អស់ដែលបណ្តាលឲ្យស្ត្រីស្លាប់បាត់បង់ជីវិត ហើយលទ្ធផលនៃការស្រាវជ្រាវបញ្ជាក់ឲ្យដឹងថា កំរិតជ្រាបច្បាស់កាន់ខ្ពស់នេះ អាចជាកត្តាធ្វើឲ្យស្ត្រីយើងអាចចាត់វិធានការណ៍ហាត់ប្រាណ, ទទួលទានអាហារដែលនាំមកនូវសុខភាពល្អ, និងធ្វើឲ្យស្រកទម្ងន់។

*អត្ថបទនេះដកស្រង់និងបកប្រែចេញពីពត៌មាននៃមជ្ឈមណ្ឌលជាតិផ្តល់ពត៌មានផ្នែកសុខភាពស្ត្រីនៃក្រសួងសហរដ្ឋទទួលបន្ទុកខាងកិច្ចសុខភាពនិងមនុស្សធម៌ (The National Women’s Health Information Center of U.S Department of Health and Human Services)ដោយមណ្ឌលមេត្តា សុខភាព នៃមណ្ឌលសុខភាពសហគន៍ក្រុងឡូវែល។*

*www.4women.gov/news/english/601622.htm*